ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ១៥ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការត្រួតពិនិត្យត្លុតតាមអនាម័យ

* * * * * *

## រាជរដ្ឋាភិបាល

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលបានប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០៦០០/០០១ ចុះថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០០០ដែលប្រកាសឱ្យប្រើប្រាស់ច្បាប់ ស្តីពីការគ្រប់គ្រងគុណភាព សុវត្ថិភាពលើផលិតផល ទំនិញ និងសេវា
- បានឃើញ អនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គនាថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០០៣



W 8.1.14
Copy
[signature]

# សម្រេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

មាត្រា ១.–

អនុក្រឹត្យនេះមានគោលបំណងកំណត់ ការត្រួតពិនិត្យភូតគាមអនាម័យ ដើម្បីទប់ស្កាត់ការរីករាលដាលឆ្លងនូវសមាសភាពចង្រៃភូតគាមអនាម័យ និងសមាសភាពចង្រៃបង្កគ្រោះថ្នាក់ពីតំបន់មួយទៅតំបន់មួយទៀត ក្នុងព្រះរាជាណាចក្រកម្ពុជា ចូលចេញ ឬឆ្លងកាត់ព្រះរាជាណាចក្រកម្ពុជាតាមគ្រប់មធ្យោបាយ ដើម្បីការពារផលិតកម្មកសិកម្ម និងជីវសាស្ត្រចម្រុះ ។

មាត្រា ២.–

រាល់ការនាំយក ឬ ដឹកជញ្ជូនទំនិញដែលជាកម្មវត្ថុ នៃការត្រួតពិនិត្យភូតគាមអនាម័យ ចូល ចេញ ឬឆ្លងកាត់ព្រះរាជាណាចក្រកម្ពុជាត្រូវសុំការត្រួតពិនិត្យ និង ត្រូវគោរពតាមគ្រប់វិធានភូតគាមអនាម័យ ។

មាត្រា ៣.–

ក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ មានភារកិច្ចទទួលខុសត្រូវ លើការអនុវត្តការងារត្រួតពិនិត្យភូតគាមអនាម័យ ដោយមាននាយកដ្ឋានក្សេត្រសាស្ត្រ និងកែលំអដីកសិកម្ម ជាអ្នកអនុវត្តផ្ទាល់ នូវសមត្ថកិច្ចភូតគាមអនាម័យ ។

មាត្រា ៤.–

និយមន័យនៃពាក្យសំខាន់ៗ ដែលប្រើប្រាស់ និងមានអត្ថន័យសម្រាប់អនុក្រឹត្យនេះ ត្រូវបានកំណត់ដូចខាងក្រោម :

ក-**សមាសភាពចង្រៃ** (Pest) : សំដៅដល់គ្រប់សត្វ និងរុក្ខជាតិ ទោះជាងាប់ ឬនៅរស់ក៏ដោយ ឱ្យតែក្នុងដំណាក់កាលលូតលាស់ណាមួយវាអាចបង្កគ្រោះថ្នាក់ ឬប៉ារ៉ាស៊ីត ឬបំផ្លាញដំណាំ ។ សមាសភាពចង្រៃទាំងនោះ រាប់បញ្ចូល នូវសត្វល្អិត ចៃ កណ្តុរ ខ្យង បក្សី សីវៈដែលបង្កជម្ងឺដល់ដំណាំនិងស្មៅចង្រៃ ។

ខ-**សមាសភាពចង្រៃភូតគាមអនាម័យ** ( Plant Quarantine Pest ) : សំដៅដល់ សមាសភាពចង្រៃដែលមិនធ្លាប់មាន នៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬមាននៅទីកន្លែងកំណត់ណាមួយតែមិនទាន់មានការរីករាលដាលហើយត្រូវបាន និងកំពុងមានវិធានការកម្ចាត់ ឬបានធ្វើការកម្ចាត់ជាស្ថាពរហើយ ។



4

គ-ការត្រួតពិនិត្យភូតគាមអនាម័យ (Phytosanitary Inspection) : សំដៅដល់ការស្រាវជ្រាវ ការរុករក ការអង្កេត ការពិនិត្យ ការយកសំណាកមកវិភាគ និងធ្វើអត្តសញ្ញាណកម្មសមាសភាពចង្រៃ ក្នុងទំនិញជាកម្មវត្ថុនៃការត្រួតពិនិត្យភូតគាមអនាម័យ ដើម្បីកំណត់នូវស្ថានភាពនៃការបំផ្លាញ ។

ឃ-សមាសភាពចង្រៃបង្កគ្រោះថ្នាក់ (Dangerous Pest) : សំដៅដល់ សមាសភាពចង្រៃដែលបណ្តាល ឬអាចបណ្តាល ឱ្យមានគ្រោះថ្នាក់ដល់សេដ្ឋកិច្ចធ្ងន់ធ្ងរ ឬ បំផ្លាញធ្ងន់ធ្ងរដល់ធនធានរុក្ខជាតិ និងបរិស្ថាន ។

ង-ចម្លងសមាសភាពចង្រៃ (Infested) : សំដៅដល់ការនាំមក ឬ ផ្ទុកទៅដោយសមាសភាពចង្រៃ ។

ច-ដឹកជញ្ជូនឆ្លងកាត់ (Transit Transport ) : សំដៅដល់ការដឹកជញ្ជូនទំនិញ ជាកម្មវត្ថុនៃការត្រួតពិនិត្យភូតគាមអនាម័យ ឆ្លងកាត់ទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ។ ការដឹកជញ្ជូនឆ្លងកាត់នេះមិនរាប់បញ្ចូល ការរើទំនិញ ការឈប់ដើម្បីដាក់ទំនិញចូលក្នុងឃ្លាំង ការបើកសម្ភារៈវេចខ្ចប់ទំនិញ ឬ ការផ្លាស់ប្តូរមធ្យោបាយដឹកជញ្ជូនឡើយ ។

ឆ-ដី : សំដៅដល់ដី ឬ ល្បាយនៃសារធាតុរ៉ែ និងសារធាតុសរីរាង្គ បង្កើតបានជាមជ្ឈដ្ឋានអាចឱ្យរុក្ខជាតិដុះលូតលាស់បាន ។

ជ-តំបន់រាលដាលសមាសភាពចង្រៃ(Epidemic Area): សំដៅដល់តំបន់កំពុងមានការរាលឆ្លង សមាសភាពចង្រៃ ។

ឈ-ទំនិញ (Goods) : សំដៅដល់រុក្ខជាតិ ផលិតផលរុក្ខជាតិ ពូជរុក្ខជាតិ ឬបំណែករុក្ខជាតិដែលត្រូវបានធ្វើចរាចរ ដើម្បីធ្វើការលក់ដូរ ឬបំលាស់ផ្សេងទៀត ។

ញ-ប្រភពបង្ករការរាលឆ្លងសមាសភាពចង្រៃ ( Epidemic Nest ) : សំដៅដល់កន្លែងដែលកើតមាននូវសមាសភាពចង្រៃមួយ ឬច្រើនប្រភេទ ហើយដែលអាចរាលឆ្លងទៅក្រៅបាន ។

ដ-ផលិតផលរុក្ខជាតិ (Plant Product): សំដៅដល់ផលិតផលរុក្ខជាតិ ដែលមិនទាន់កែច្នៃ ឬ ពាក់កណ្តាលកែច្នៃ ឬ ផលិតផលដែលមានដើមកំណើតពីរុក្ខជាតិ ។

ឋ-ផលិតផលរុក្ខជាតិកែច្នៃ (Manufactured material of plant origin): សំដៅដល់ផលិតផលរុក្ខជាតិដែលទទួលការកែច្នៃពាក់កណ្តាលសម្រេច ឬសម្រេច តែចលនការកែច្នៃទាំងនោះ ពុំអាចធានាបាននូវការរាតត្បាតពីសមាសភាពចង្រៃ ក្នុងរយៈពេលបន្ទាប់ពីការកែច្នៃ ។ ផលិតផលទាំងនេះ ពុំរាប់បញ្ចូលនូវផលិតផលកែច្នៃទាំងឡាយណា ដែលបានធ្វើការវេចខ្ចប់ចូលទៅក្នុងកំប៉ុង ឬ កែវបិតជិត ឬមានសំបកវិចខ្ចប់ ដែលការពារបាននូវការចម្លងរោគផ្សេងៗ ។

ឌ-ភូតគាមអនាម័យ ( Phytosanitary ) : សំដៅដល់វិធានការបង្កាទប់ស្កាត់ ការរាតត្បាតពីសំណាក់សមាសភាពចង្រៃលើរុក្ខជាតិ ។

ឍ-មន្ត្រីភូតគាមអនាម័យ (Phytosanitary Officer) : សំដៅដល់មន្ត្រីដែលតែងតាំងដើម្បីឱ្យធ្វើការងារត្រួតពិនិត្យភូតគាមអនាម័យ ។



hc

ណ-រុក្ខជាតិ (Plant) ៖សំដៅដល់គ្រប់រុក្ខជាតិទាំងអស់ ងាប់ ឬ រស់ និងគ្រប់ផ្នែកណាក់កាលលូតលាស់ (ដំណុះ ឬ វគ្គលូតលាស់ណាមួយដូចជា ៖ គ្រាប់ពូជ ឫស មើម ពកឫស ដើម ផ្លាំង ផ្កា ផ្លែ ស្លឹក សំបក លើកលែងផលិតផលកំប៉ុង ) ។

ត-លក្ខខណ្ឌភូតគាមអនាម័យ (Phytosanitary Requirement) ៖ សំដៅដល់លក្ខខណ្ឌទាមទាររបស់សមត្ថកិច្ចភូតគាមអនាម័យ នៃប្រទេសនីមួយៗ ដើម្បីបង្កាទប់ស្កាត់ការឆ្លងរាលដាលចូលមក ក្នុងប្រទេសនូវសមាសភាពចង្រៃ តាមសកម្មភាពនាំចូលនូវទំនិញ ជាកម្មវត្ថុនៃការត្រួតពិនិត្យភូតគាមអនាម័យ ។

ការទាមទារនេះផ្អែកលើអនុសញ្ញាការពារដំណាំអន្តរជាតិ ឆ្នាំ ១៩៥១ ។

ថ-វិញ្ញាបនបត្រភូតគាមអនាម័យ ( Phytosanitary Certificate ) ៖ សំដៅដល់វិញ្ញាបនបត្រដែលផ្តល់ឱ្យដោយសមត្ថកិច្ចភូតគាមអនាម័យ បន្ទាប់ពីបានធ្វើការត្រួតពិនិត្យភូតគាមអនាម័យ លើទំនិញមុនពេលនាំចេញពីព្រះរាជាណាចក្រកម្ពុជា ដោយអនុលោមទៅតាមគំរូ ដែលបានចែងក្នុងអនុសញ្ញាស្តីពីការងារការពារដំណាំអន្តរជាតិនាឆ្នាំ ១៩៥១ ។ វិញ្ញាបនបត្រភូតគាមអនាម័យ ជាការទាមទារដ៏ចាំបាច់ដើម្បីភ្ជាប់មកជាមួយ នូវរាល់ការនាំចូល ការនាំចេញ និងការដឹកជញ្ជូនឆ្លងកាត់ នូវទំនិញជាកម្មវត្ថុភូតគាមអនាម័យ ។

វិញ្ញាបនបត្រនេះមានទម្រង់តាមគំរូ ដែលមានចែងក្នុងអនុសញ្ញាស្តីពីការងារការពារដំណាំអន្តរជាតិ នាឆ្នាំ ១៩៥១ ។

ទ-វិញ្ញាបនបត្រភូតគាមអនាម័យសម្រាប់បន្តការនាំចេញ (Phytosanitary Certificate for Re-export)៖ សំដៅដល់វិញ្ញាបនប័ត្រដែលផ្តល់ឱ្យដោយអង្គភាពត្រួតពិនិត្យភូតគាមអនាម័យ ចំពោះទំនិញជាកម្មវត្ថុនៃការត្រួត ពិនិត្យភូតគាមអនាម័យដែលនាំពីប្រទេសផ្សេងចូលមករក្សាទុក ឬបំបែកជាផ្នែក ឬ ដើម្បីបញ្ចូលបន្ថែម ឬគ្រាន់តែ ប្តូរសម្ភារៈវេចខ្ចប់ ឬមានការបើកសម្ភារៈវេចខ្ចប់ក្នុងអំឡុងពេលដឹកនាំឆ្លងកាត់ប្រទេស ដែលមិនមែនជាប្រភពដើម ដើម្បីបន្តការនាំចេញទៅកាន់ប្រទេសទីបី ។

ធ-វិធានភូតគាមអនាម័យ (Phytosanitary Treatment) ៖ សំដៅដល់ជម្រើស ការកម្ចាត់ សមាសភាពចង្រៃ ការកែច្នៃឡើងវិញ ការសម្អាត ការផ្តាច់មិនឱ្យឆ្លងបាន ការឃាត់ទុក ការបញ្ជូនត្រឡប់ទៅប្រភពដើម ឬការកម្ទេចចោលទំនិញ ជាកម្មវត្ថុនៃការត្រួតពិនិត្យភូតគាមអនាម័យ ។

ន-សរីរៈមានប្រយោជន៍ (Beneficial Organism) ៖ សំដៅដល់គ្រប់សរីរៈដែលផ្តល់ប្រយោជន៍ដល់ការដុះលូតលាស់នៃរុក្ខជាតិ ដោយកម្ចាត់សមាសភាពចង្រៃបំផ្លាញដំណាំ តាមរយៈការធ្វើប៉ារ៉ាស៊ីត ការចាប់ធ្វើជាចំណី និងការចម្លងរោគផ្សេងៗ ។ សរីរៈមានប្រយោជន៍ទាំងនោះរាប់បញ្ចូលនូវពពួកសត្វល្អិតចៃ ឈាមកួត ផ្សិត បាក់តេរី វីរុស និងមីក្រូសរីរាង្គផ្សេងៗទៀត ។ សរីរៈមានប្រយោជន៍ដែលរៀបរាប់ខាងលើនេះ ជាសត្រូវធម្មជាតិ ដែលអាចកម្ចាត់ពពួកសមាសភាពចង្រៃលើដំណាំ ។

ប-សមត្ថកិច្ចភូតគាមអនាម័យ(Plant Quarantine Authority) ៖ សំដៅដល់អង្គភាពទទួលបន្ទុកការងារត្រួតពិនិត្យភូតគាមអនាម័យ ដែលមានវេទនាសម្ព័ន្ធច្បាស់លាស់ តាំងពីថ្នាក់កណ្តាលរហូតដល់ទីស្នាក់ការត្រួតពិនិត្យភូតគាមអនាម័យនានា ។បច្ចុប្បន្នអង្គភាពនេះជាការិយាល័យការពារដំណាំ និងត្រួតពិនិត្យភូតគាមអនាម័យ ដែល

ស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់របស់នាយកដ្ឋានក្សេត្រសាស្ត្រ និងកែលំអដីកសិកម្ម នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។ អង្គភាពនេះមានទំនាក់ទំនងការងារ និងសហប្រតិបត្តិការជិតស្និទ្ធជាប្រចាំ ជាមួយអង្គភាពភូតគាមអនាម័យនៃបណ្តាប្រទេសផ្សេងទៀត ដែលអនុវត្តអនុសញ្ញាការពាររុក្ខជាតិអន្តរជាតិឆ្នាំ ១៩៥១ ។

ជ-ស្ថានភាពនៃការរាតត្បាត (Infection Status) : សំដៅដល់កម្រិត និងលក្ខណៈនៃការរាតត្បាតលើទំនិញជាកម្មវត្ថុ នៃការត្រួតពិនិត្យភូតគាមអនាម័យ ដោយសមាសភាពចង្រៃ ។

## ជំពូកទី ២
## ការត្រួតពិនិត្យភូតគាមអនាម័យ

**មាត្រា ៥.-**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវចាត់បញ្ជូនមន្ត្រីភូតគាមអនាម័យ និងមន្ត្រីត្រួតពិនិត្យអនាម័យសត្វនិងផលិតផលដែលមានដើមកំណើតពីសត្វ ឱ្យទៅចូលរួមបំពេញភារកិច្ចត្រួតពិនិត្យ តាមសមត្ថកិច្ចរៀងៗខ្លួន នៅតាមទីស្នាក់ការត្រួតពិនិត្យច្រកទ្វារអន្តរជាតិ ច្រកទ្វារព្រំដែនអន្តរជាតិ ច្រកទ្វារព្រំដែនទ្វេភាគី ច្រកទ្វារតំបន់ព្រំដែន និងច្រកទ្វារកំពង់ផែសមុទ្រ នៅទូទាំងព្រះរាជាណាចក្រកម្ពុជា តាមការកំណត់របស់រាជរដ្ឋាភិបាល ដោយអនុក្រឹត្យ ។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អាចបង្កើតទីស្នាក់ការត្រួតពិនិត្យភូតគាមអនាម័យ អនាម័យសត្វ និងផលិតផលដែលមានដើមកំណើតពីសត្វ នៅតាមស្ថានីយ៍រថភ្លើង កំពង់ផែស្ងួត កំពង់ផែ និងអាកាសយានដ្ឋានក្នុងស្រុកតាមការអនុញ្ញាតរបស់រាជរដ្ឋាភិបាល ។

ក្នុងករណីដែលមានការរាលដាលឆ្លង សមាសភាពចង្រៃភូតគាមអនាម័យ ឬសមាសភាពចង្រៃបង្កគ្រោះថ្នាក់ នៅតំបន់ណាមួយក្នុងទឹកដីនៃព្រះរាជាណាចក្រកម្ពុជា នោះរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវចេញប្រកាសបង្កើតស្នាក់ការត្រួតពិនិត្យភូតគាមអនាម័យបណ្តោះអាសន្ន ជាបន្ទាន់ នៅតាមទីតាំងចាំបាច់ ដើម្បីទប់ស្កាត់ការរាលដាលឆ្លង និងអនុវត្តវិធានភូតគាមអនាម័យ ដើម្បីកំចាត់បញ្ហា។ នៅពេលដែលការរាតត្បាត ត្រូវបានលុបបំបាត់ នោះរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវចេញប្រកាសរំសាយស្នាក់ការត្រួតពិនិត្យភូតគាមអនាម័យបណ្តោះអាសន្នទាំងនោះ ។

ទីស្នាក់ការត្រួតពិនិត្យភូតគាមអនាម័យ ត្រូវបំពាក់ដោយសម្ភារៈឧបករណ៍បច្ចេកទេសសមស្រប ធានាបាននូវប្រសិទ្ធភាព នៃការត្រួតពិនិត្យភូតគាមអនាម័យ ។

ទីស្នាក់ការត្រួតពិនិត្យភូតគាមអនាម័យ ត្រូវមានទីតាំងសមស្រប ដើម្បីបង្កភាពងាយស្រួលដល់សកម្មភាពដឹកជញ្ជូនទំនិញជាកម្មវត្ថុ នៃការត្រួតពិនិត្យភូតគាមអនាម័យ ។

ទីស្នាក់ការត្រួតពិនិត្យភូតគាមអនាម័យ ត្រូវបំពាក់ដោយសម្ភារៈឧបករណ៍បច្ចេកទេសសមស្រប ធានាបាន នូវប្រសិទ្ធភាព នៃការត្រួតពិនិត្យភូតគាមអនាម័យ ។

ទីស្នាក់ការត្រួតពិនិត្យភូតគាមអនាម័យ ត្រូវមានទីតាំងសមស្រប ដើម្បីបង្កភាពងាយស្រួលដល់សកម្មភាព ដឹកជញ្ជូនទំនិញជាកម្មវត្ថុ នៃការត្រួតពិនិត្យភូតគាមអនាម័យ ។

មាត្រា ៦.-

ការត្រួតពិនិត្យភូតគាមអនាម័យ ត្រូវអនុវត្តតាមលក្ខខណ្ឌភូតគាមអនាម័យនៃប្រទេសនីមួយៗ ។

មាត្រា ៧.-

ទំនិញជាកម្មវត្ថុនៃការត្រួតពិនិត្យភូតគាមអនាម័យមាន :

- រុក្ខជាតិ បំណែករុក្ខជាតិ ផលិតផលរុក្ខជាតិ និងផលិតផលកែច្នៃពីផលិតផលរុក្ខជាតិ ដែលអាចជាជម្រក និងចម្លងសមាសភាពចង្រៃ
- សម្ភារៈវេចខ្ចប់ ឡាំងឈើ កំណាត់ឈើ ឬមធ្យោបាយដឹកជញ្ជូនគ្រប់ប្រភេទ និងឃ្លាំងសន្និធិ
- ដី ឬ ដីដែលជាប់ នឹងឫស ឬ បំណែករុក្ខជាតិ
- កត្តាចង្រៃ ឬសរីរៈមានប្រយោជន៍ រស់ ឬងាប់
- ផលិតផលដែលគ្មានដើមកំណើតពីរុក្ខជាតិ តែអាចជាជម្រកនៃសមាសភាពចង្រៃ ។

បញ្ជីមុខទំនិញជាកម្មវត្ថុនៃការត្រួតពិនិត្យភូតគាមអនាម័យ ត្រូវកំណត់ដោយប្រកាសរួម របស់រដ្ឋមន្ត្រី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល និងរដ្ឋមន្ត្រីក្រសួងសុខាភិបាល ។

មាត្រា ៨.-

ម្ចាស់ទំនិញជាកម្មវត្ថុនៃការត្រួតពិនិត្យភូតគាមអនាម័យ ត្រូវអនុវត្តតាមនីតិវិធីដូចខាងក្រោម:

- ត្រូវធ្វើប្រតិវេទន៍ទំនិញឱ្យបានត្រឹមត្រូវ
- ត្រូវមានវិញ្ញាបនបត្រភូតគាមអនាម័យ
- ត្រូវវេចខ្ចប់ទំនិញ និងធានាសុវត្ថិភាពមិនឱ្យធ្លុះធ្លាយ ឬកំពប់រាយប៉ាយតាមផ្លូវក្នុងពេលដឹកជញ្ជូន
- ត្រូវទុកដាក់ ឬ ដឹកទំនិញតាមទិសដៅកំណត់របស់សមត្ថកិច្ចភូតគាមអនាម័យ ។

ក្នុងករណីមានការដឹកជញ្ជូនរក្សាទុក ឬដាក់ទំនិញខុសពីទិសដៅកំណត់ ត្រូវសុំការអនុញ្ញាតពីសមត្ថកិច្ចភូត គាមអនាម័យ ។



lk

មាត្រា ៩.-

មុនពេលទំនិញចូលមកដល់ច្រកទ្វារព្រំដែន រូបវន្តបុគ្គល ឬ នីតិបុគ្គល ដែលជាម្ចាស់ទំនិញត្រូវជូនដំណឹងទៅទីស្នាក់ការត្រួតពិនិត្យភូតគាមអនាម័យ ដែលនៅជិតបំផុត ហើយត្រូវបង្កលក្ខណៈងាយស្រួលដល់ការត្រួតពិនិត្យភូតគាមអនាម័យ ។ ក្នុងរយៈពេលម្ភៃបួនម៉ោង( ២៤ម៉ោង ) ក្រោយពីបានទទួលដំណឹង ទីស្នាក់ការត្រួតពិនិត្យភូតគាមអនាម័យ ត្រូវធ្វើការត្រួតពិនិត្យឱ្យបានចប់សព្វគ្រប់ ។

ក្នុងរយៈពេលដប់ថ្ងៃ( ១០ថ្ងៃ) មុននាំទំនិញចេញ រូបវន្តបុគ្គល ឬនីតិបុគ្គលដែលជាម្ចាស់ទំនិញ ត្រូវដាក់ពាក្យស្នើសុំត្រួតពិនិត្យភូតគាមអនាម័យ មកសមត្ថកិច្ចភូតគាមអនាម័យដែលនៅជិតបំផុត ហើយត្រូវបង្កលក្ខណៈងាយស្រួលដល់ការត្រួតពិនិត្យភូតគាមអនាម័យ ។ ក្នុងរយៈពេលនេះ សមត្ថកិច្ចភូតគាមអនាម័យ ត្រូវបញ្ចប់ការត្រួតពិនិត្យ និងការអនុវត្តវិធានភូតគាមអនាម័យ ឱ្យបានចប់សព្វគ្រប់ ។

មាត្រា១០.-

ចំពោះទំនិញជាកម្មវត្ថុនៃការត្រួតពិនិត្យភូតគាមអនាម័យ ដែលមិនសមស្របតាមលក្ខខណ្ឌភូតគាមអនាម័យនៃប្រទេសនាំចូល ម្ចាស់ទំនិញត្រូវអនុវត្តតាមវិធានភូតគាមអនាម័យនៃប្រទេសនាំចូលនោះ ។

ការចំណាយលើវិធានភូតគាមអនាម័យខាងលើ ជាបន្ទុករបស់ម្ចាស់ទំនិញ ។

មាត្រា ១១.-

រូបវន្តបុគ្គល ឬនីតិបុគ្គលអាចផ្តល់ព័ត៌មានដល់សមត្ថកិច្ចភូតគាមអនាម័យ ដែលនៅជិតបំផុតក្នុងករណីដែលបានឃើញ:

ក. កប៉ាល់ កាណូត ទូក ឬ មធ្យោបាយដឹកជញ្ជូនផ្សេងៗទៀត ដែលមានទំនិញជាកម្មវត្ថុនៃការត្រួតពិនិត្យភូតគាមអនាម័យលេចធ្លាយ ឬ ខូចគ្រឿងចក្ររសាត់អណ្តែត ឬ បើកឆ្លងចូលមកដែនទឹក ដី នៃព្រះរាជាណាចក្រកម្ពុជា ។

ខ. ទំនិញជាកម្មវត្ថុនៃការត្រួតពិនិត្យភូតគាមអនាម័យ ដែលយន្តហោះបានទម្លាក់មកលើទឹក ដី នៃព្រះរាជាណាចក្រកម្ពុជា។

មាត្រា ១២.-

រូបវន្តបុគ្គល ឬនីតិបុគ្គលជាម្ចាស់ទំនិញ ត្រូវចាត់វិធានការកម្ចាត់ជាបន្ទាន់ នៅពេលដែលបានឃើញ ឬដឹងថាទំនិញ របស់ខ្លួនមានសមាសភាពចង្រៃភូតគាមអនាម័យ។ ក្នុងករណីដែលពុំមានលទ្ធភាពកម្ចាត់ទេនោះ ម្ចាស់ទំនិញចាំបាច់ ត្រូវស្នើសុំសមត្ថកិច្ចភូតគាមអនាម័យ ដើម្បីអនុវត្តវិធានភូតគាមអនាម័យនេះ ។

មាត្រា ១៣._

បើមានសមាសភាពចង្រៃរាតត្បាត នៅតាមទីស្នាក់ការត្រួតពិនិត្យណាមួយនោះ មន្ត្រីភូតគាមអនាម័យ ត្រូវចាត់វិធានការសមស្របដើម្បីកម្ចាត់ជាបន្ទាន់ ចៀសវាងធ្វើឱ្យរាំងស្ទះដល់ការចរាចរទំនិញ ។

ក្នុងករណីវិធានការខាងលើ មិនទាន់ទទួលបានប្រសិទ្ធភាពទេនោះ សមត្ថកិច្ចភូតគាមអនាម័យ ត្រូវបញ្ឈប់ការដឹកជញ្ជូនឆ្លងកាត់ ការផ្ទុក ឬរើទំនិញជាបណ្ដោះអាសន្នរហូត ដល់សមាសភាពចង្រៃ ត្រូវបានកម្ចាត់ទាំងស្រុង ។

មាត្រា ១៤._

រូបវន្តបុគ្គល ឬនីតិបុគ្គល ដែលបានស្នើសុំធ្វើការត្រួតពិនិត្យភូតគាមអនាម័យ លើទំនិញរបស់ខ្លួនត្រូវបង់សោហ៊ុយសេវាកម្មត្រួតពិនិត្យភូតគាមអនាម័យ ។ ប្រសិនបើស្នើឱ្យធ្វើការកម្ចាត់សមាសភាពចង្រៃនោះ ត្រូវបង់សោហ៊ុយសេវាកម្មកម្ចាត់សមាសភាពចង្រៃ ។ សោហ៊ុយសេវាកម្មទាំងនេះត្រូវបង់ចូលថវិកាជាតិ តាមរយៈសមត្ថកិច្ចភូតគាមអនាម័យ ។

សោហ៊ុយសេវាកម្មត្រួតពិនិត្យភូតគាមអនាម័យ និងសោហ៊ុយសេវាកម្មកម្ចាត់សមាសភាពចង្រៃ ត្រូវកំណត់ដោយ ប្រកាសរួមរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

មាត្រា ១៥._

នៅគ្រប់ទីស្នាក់ការត្រួតពិនិត្យទំនិញ ជាកម្មវត្ថុនៃការត្រួតពិនិត្យភូតគាមអនាម័យ នាំចេញ នាំចូល និងឆ្លងកាត់ ត្រូវមានការរួមសហការរវាងអង្គភាពពាក់ព័ន្ធដូចតទៅ :

១.ប្រធានគ្រប់គ្រងច្រកទ្វារ ប្រធានស្នាក់ការត្រួតពិនិត្យ និងគ្រប់ស្ថាប័នពាក់ព័ន្ធនឹងការងារត្រួតពិនិត្យត្រូវរួមសហការជាមួយមន្ត្រីភូតគាមអនាម័យ ក្នុងការបង្ការទប់ស្កាត់ និងអនុវត្តវិធានភូតគាមអនាម័យ ។

២.ការត្រួតពិនិត្យភូតគាមអនាម័យ ត្រូវធ្វើឡើងក្នុងពេលតែមួយជាមួយសមត្ថកិច្ចគយ-រដ្ឋាករ និងកាំកុងត្រូល ។

មាត្រា ១៦._

ក្នុងពេលប្រតិបត្តិការ មន្ត្រីភូតគាមអនាម័យត្រូវស្លៀកពាក់ឯកសណ្ឋាន ពាក់សញ្ញាសម្គាល់ និងមានលិខិតបញ្ជាបេសកកម្ម របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទជាប់នឹងខ្លួន ។

ឯកសណ្ឋាន សញ្ញាសម្គាល់ និងត្រា របស់សមត្ថកិច្ចភូតគាមអនាម័យ ត្រូវកំណត់ដោយអនុក្រឹត្យមួយដោយឡែក ។

រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវចេញប្រកាសអំពីនីតិវិធី នៃការត្រួតពិនិត្យភូតគាមអនាម័យ ឬសារាចរណែនាំផ្សេងទៀត ដើម្បីឱ្យដំណើរការនៃការអនុវត្តអនុក្រឹត្យនេះ ប្រព្រឹត្តទៅប្រកបដោយប្រសិទ្ធភាពតម្លាភាព និងគ្មានភាពរើសអើងនៅក្នុងទូទាំងព្រះរាជាណាចក្រកម្ពុជា។

មាត្រា ១៧.-

រាល់ប្រកាស ឬ សារាចរណែនាំពាក់ព័ន្ធ នឹងការងារត្រួតពិនិត្យភូតគាមអនាម័យ ត្រូវធ្វើការផ្សព្វផ្សាយជាសាធារណៈតាមរយៈប្រព័ន្ធផ្សព្វផ្សាយជាតិ ។

## ជំពូកទី ៣
## ការត្រួតពិនិត្យភូតគាមអនាម័យក្នុងស្រុក

មាត្រា ១៨.-

ពេលមានប្រភពបង្កការរាលឆ្លង សមាសភាពចង្រៃភូតគាមអនាម័យ ឬ សមាសភាពចង្រៃបង្កគ្រោះថ្នាក់នៅតំបន់ណាមួយក្នុងទឹកដី នៃព្រះរាជាណាចក្រកម្ពុជា រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវប្រកាសជាតំបន់រាលឆ្លងសមាសភាពចង្រៃភូតគាមអនាម័យ ឬ សមាសភាពចង្រៃបង្កគ្រោះថ្នាក់ និងត្រូវអនុវត្តវិធានភូតគាមអនាម័យ ដើម្បីកម្ចាត់ជាបន្ទាន់។

ការដឹកទំនិញចេញ ចូល ឬ ឆ្លងកាត់តំបន់រាលឆ្លងកត្តាចង្រៃភូតគាមអនាម័យ ឬ សមាសភាពចង្រៃបង្កគ្រោះថ្នាក់ ត្រូវផ្អាកជាបណ្ដោះអាសន្នរហូតដល់មានប្រកាសជាថ្មី របស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

មាត្រា ១៩.-

ការនាំយកសំណាក សមាសភាពចង្រៃភូតគាមអនាម័យ ឬសមាសភាពចង្រៃបង្កគ្រោះថ្នាក់ ពីតំបន់រាលឆ្លងសមាសភាពចង្រៃទៅតំបន់ ដែលគ្មានការរាតត្បាតដើម្បីធ្វើការសិក្សាស្រាវជ្រាវ ត្រូវតែមានការអនុញ្ញាតពីសមត្ថកិច្ចភូតគាមអនាម័យ ។



ហក

## ជំពូកទី ៤

## ការត្រួតពិនិត្យភូតគាមអនាម័យ លើទំនិញនាំចូល និងការឆ្លងដាន

មាត្រា ២០.-

ការត្រួតពិនិត្យលើការនាំចូលទំនិញ ជាកម្មវត្ថុនៃការត្រួតពិនិត្យភូតគាមអនាម័យ ត្រូវអនុវត្តដោយផ្អែកលើបញ្ជីរាយឈ្មោះ សមាសភាពចង្រៃភូតគាមអនាម័យ និងសមាសភាពចង្រៃបង្កគ្រោះថ្នាក់ ដែលត្រូវហាមឃាត់ឱ្យចូលក្នុងទឹកដី នៃព្រះរាជាណាចក្រកម្ពុជា ។

បញ្ជីរាយឈ្មោះសមាសភាពចង្រៃភូតគាមអនាម័យ និងសមាសភាពចង្រៃបង្កគ្រោះថ្នាក់ ដែលត្រូវហាមឃាត់ឱ្យចូលក្នុងទឹកដី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានសិទ្ធិកែប្រែបញ្ជីរាយឈ្មោះ សមាសភាពចង្រៃភូតគាមអនាម័យ និង សមាសភាពចង្រៃបង្កគ្រោះថ្នាក់ ដែលត្រូវហាមឃាត់ឱ្យចូលក្នុងទឹកដី នៃព្រះរាជាណាចក្រកម្ពុជាតាមការចាំបាច់ ។ ការកែប្រែនេះនឹងមានសុពលភាព បន្ទាប់ពីការផ្សព្វផ្សាយជាសាធារណៈរយៈពេលសាមសិបថ្ងៃ (៣០ថ្ងៃ) ។ ក្នុងករណីចាំបាច់ និងបន្ទាន់ដែលមានការបង្កគ្រោះថ្នាក់លើវិស័យកសិកម្ម និងជីវសាស្ត្រចម្រុះនោះ ការផ្លាស់ប្តូរបញ្ជីរាយឈ្មោះ សមាសភាពចង្រៃភូតគាមអនាម័យ និងសមាសភាពចង្រៃបង្កគ្រោះថ្នាក់ ដែលត្រូវហាមឃាត់ឱ្យចូលក្នុងទឹកដី នៃព្រះរាជាណាចក្រកម្ពុជា នឹងមានសុពលភាពម្ភៃបួនម៉ោង (២៤ ម៉ោង) បន្ទាប់ពីបានផ្សព្វផ្សាយជាសាធារណៈ ។

មាត្រា ២១.-

ម្ចាស់ទំនិញដែលនាំទំនិញ ជាកម្មវត្ថុនៃការត្រួតពិនិត្យភូតគាមអនាម័យ ចូលក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវគោរពតាមលក្ខខណ្ឌភូតគាមអនាម័យ ដូចខាងក្រោម :

១.មានវិញ្ញាបនបត្រភូតគាមអនាម័យ ចេញដោយសមត្ថកិច្ចភូតគាមអនាម័យ នៃប្រទេសនាំចេញតាមគំរូដូចបានកំណត់ ដោយអនុសញ្ញាការពារដំណាំអន្តរជាតិ ឆ្នាំ ១៩៥១ ។

២.ពុំមានចម្លងមកជាមួយ នូវសមាសភាពចង្រៃភូតគាមអនាម័យ និងបណ្តាសមាសភាពចង្រៃបង្កគ្រោះថ្នាក់ដទៃទៀត នៃព្រះរាជាណាចក្រកម្ពុជា ។ ក្នុងករណីមានការរាតត្បាត ពីសមាសភាពចង្រៃខាងលើ ត្រូវអនុវត្តវិធានភូតគាមអនាម័យមុនពេលនាំចូល ។

រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវចេញប្រកាសអំពីនីតិវិធី នៃការត្រួតពិនិត្យភូតគាមអនាម័យ ឬសារាចរណែនាំផ្សេងទៀត ដើម្បីឱ្យដំណើរការនៃការអនុវត្តអនុក្រឹត្យនេះ ប្រព្រឹត្តទៅប្រកបដោយប្រសិទ្ធភាពតម្លាភាព និងគ្មានភាពរើសអើងនៅក្នុងទូទាំងព្រះរាជាណាចក្រកម្ពុជា។

មាត្រា ១៧.-

រាល់ប្រកាស ឬ សារាចរណែនាំពាក់ព័ន្ធ នឹងការងារត្រួតពិនិត្យភូតគាមអនាម័យ ត្រូវធ្វើការផ្សព្វផ្សាយជាសាធារណៈតាមរយៈប្រព័ន្ធផ្សព្វផ្សាយជាតិ ។

## ជំពូកទី ៣
## ការត្រួតពិនិត្យភូតគាមអនាម័យក្នុងស្រុក

មាត្រា ១៨.-

ពេលមានប្រភពបង្កការរាលឆ្លង សមាសភាពចង្រៃភូតគាមអនាម័យ ឬ សមាសភាពចង្រៃបង្កគ្រោះថ្នាក់នៅតំបន់ណាមួយក្នុងទឹកដី នៃព្រះរាជាណាចក្រកម្ពុជា រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវប្រកាសជាតំបន់រាលឆ្លងសមាសភាពចង្រៃភូតគាមអនាម័យ ឬ សមាសភាពចង្រៃបង្កគ្រោះថ្នាក់ និងត្រូវអនុវត្តវិធានភូតគាមអនាម័យ ដើម្បីកម្ចាត់ជាបន្ទាន់។

ការដឹកទំនិញចេញ ចូល ឬ ឆ្លងកាត់តំបន់រាលឆ្លងកត្តាចង្រៃភូតគាមអនាម័យ ឬ សមាសភាពចង្រៃបង្កគ្រោះថ្នាក់ ត្រូវផ្អាកជាបណ្ដោះអាសន្នរហូតដល់មានប្រកាសជាថ្មី របស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

មាត្រា ១៩.-

ការនាំយកសំណាក សមាសភាពចង្រៃភូតគាមអនាម័យ ឬសមាសភាពចង្រៃបង្កគ្រោះថ្នាក់ ពីតំបន់រាលឆ្លងសមាសភាពចង្រៃទៅតំបន់ ដែលគ្មានការរាតត្បាតដើម្បីធ្វើការសិក្សាស្រាវជ្រាវ ត្រូវតែមានការអនុញ្ញាតពីសមត្ថកិច្ចភូតគាមអនាម័យ ។

## ជំពូកទី ៤
## ការត្រួតពិនិត្យភូតគាមអនាម័យ លើទំនិញនាំចូល និងការឆ្លងកាត់

មាត្រា ២០.-

ការត្រួតពិនិត្យលើការនាំចូលទំនិញ ជាកម្មវត្ថុនៃការត្រួតពិនិត្យភូតគាមអនាម័យ ត្រូវអនុវត្តដោយផ្អែកលើបញ្ជីរាយឈ្មោះ សមាសភាពចង្រៃភូតគាមអនាម័យ និងសមាសភាពចង្រៃបង្កគ្រោះថ្នាក់ ដែលត្រូវហាមឃាត់ឱ្យចូលក្នុងទឹកដី នៃព្រះរាជាណាចក្រកម្ពុជា ។

បញ្ជីរាយឈ្មោះសមាសភាពចង្រៃភូតគាមអនាម័យ និងសមាសភាពចង្រៃបង្កគ្រោះថ្នាក់ ដែលត្រូវហាមឃាត់ឱ្យចូលក្នុងទឹកដី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានសិទ្ធិកែប្រែបញ្ជីរាយឈ្មោះ សមាសភាពចង្រៃភូតគាមអនាម័យ និង សមាសភាពចង្រៃបង្កគ្រោះថ្នាក់ ដែលត្រូវហាមឃាត់ឱ្យចូលក្នុងទឹកដី នៃព្រះរាជាណាចក្រកម្ពុជាតាមការចាំបាច់ ។ ការកែប្រែនេះនឹងមានសុពលភាព បន្ទាប់ពីការផ្សព្វផ្សាយជាសាធារណៈរយៈពេលសាមសិបថ្ងៃ (៣០ថ្ងៃ) ។ ក្នុងករណីចាំបាច់ និងបន្ទាន់ដែលមានការបង្កគ្រោះថ្នាក់លើវិស័យកសិកម្ម និងជីវសាស្ត្រចម្រុះនោះ ការផ្លាស់ប្តូរបញ្ជីរាយឈ្មោះ សមាសភាពចង្រៃភូតគាមអនាម័យ និងសមាសភាពចង្រៃបង្កគ្រោះថ្នាក់ ដែលត្រូវហាមឃាត់ឱ្យចូលក្នុងទឹកដី នៃព្រះរាជាណាចក្រកម្ពុជា នឹងមានសុពលភាពម្ភៃបួនម៉ោង (២៤ ម៉ោង) បន្ទាប់ពីបានផ្សព្វផ្សាយជាសាធារណៈ ។

មាត្រា ២១.-

ម្ចាស់ទំនិញដែលនាំទំនិញ ជាកម្មវត្ថុនៃការត្រួតពិនិត្យភូតគាមអនាម័យ ចូលក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវគោរពតាមលក្ខខណ្ឌភូតគាមអនាម័យ ដូចខាងក្រោម :

១.មានវិញ្ញាបនបត្រភូតគាមអនាម័យ ចេញដោយសមត្ថកិច្ចភូតគាមអនាម័យ នៃប្រទេសនាំចេញតាមគំរូដូចបានកំណត់ ដោយអនុសញ្ញាការពារដំណាំអន្តរជាតិ ឆ្នាំ ១៩៥១ ។

២.ពុំមានចម្លងមកជាមួយ នូវសមាសភាពចង្រៃភូតគាមអនាម័យ និងបណ្តាសមាសភាពចង្រៃបង្កគ្រោះថ្នាក់ដទៃទៀត នៃព្រះរាជាណាចក្រកម្ពុជា ។ ក្នុងករណីមានការភាគត្បាត ពីសមាសភាពចង្រៃខាងលើ ត្រូវអនុវត្តវិធានភូតគាមអនាម័យមុនពេលនាំចូល ។

មាត្រា ២២.-

បែបបទនៃការត្រួតពិនិត្យទំនិញ ជាកម្មវត្ថុនៃការត្រួតពិនិត្យភូតគាមអនាម័យ នាំចូលត្រូវកំណត់ដូចតទៅ :

១.រូបវន្តបុគ្គល ឬ នីតិបុគ្គលដែលនឹងនាំចូលនូវរុក្ខជាតិ ត្រូវជូនដំណឹងដល់ទីស្នាក់ការត្រួតពិនិត្យភូតគាមអនាម័យ ដែលត្រូវឆ្លងចូល យ៉ាងតិចដប់ថ្ងៃ ( ១០ថ្ងៃ ) មុនពេលមកដល់ ។

២.នៅពេលមកដល់ច្រកទ្វារព្រំដែនទីមួយ នៃព្រះរាជាណាចក្រកម្ពុជា ម្ចាស់ទំនិញជាកម្មវត្ថុនៃការត្រួតពិនិត្យភូតគាមអនាម័យ ត្រូវរាយការណ៍ និងសុំការត្រួតពិនិត្យភូតគាមអនាម័យ ។ ទីស្នាក់ការត្រួតពិនិត្យភូតគាមអនាម័យត្រូវកំណត់ទីកន្លែងសមស្របតាមលក្ខណៈបច្ចេកទេស ដើម្បីធ្វើការត្រួតពិនិត្យភូតគាមអនាម័យ ។

ការធ្វើប្រតិវេទន៍ ការត្រួតពិនិត្យ និងការអនុវត្តវិធានភូតគាមអនាម័យ ត្រូវអនុវត្តតាមលក្ខខណ្ឌភូតគាមអនាម័យ ដូចមានចែងក្នុងមាត្រា៩ មាត្រា១០ និង មាត្រា១៤ នៃអនុក្រឹត្យនេះ ។ ចំពោះការបញ្ជូនត្រឡប់ទៅប្រភពដើម ឬការកម្ទេចចោលទំនិញជាកម្មវត្ថុ នៃការត្រួតពិនិត្យភូតគាមអនាម័យ ត្រូវមានវិធានការតាមច្បាប់ជាធរមាន ។

ចំពោះទំនិញចូលមកដល់ដែនទឹក នៃព្រះរាជាណាចក្រកម្ពុជា ម្ចាស់ទំនិញជាកម្មវត្ថុនៃការត្រួតពិនិត្យភូតគាមអនាម័យ ដែលដឹកជញ្ជូនតាមផ្លូវទឹក ត្រូវរាយការណ៍ជូនស្នាក់ការភូតគាមអនាម័យ ដែលនៅជិតបំផុតដើម្បីសុំការត្រួតពិនិត្យ ។ មធ្យោបាយដឹកជញ្ជូនទំនិញដែលជាកម្មវត្ថុនៃការត្រួតពិនិត្យភូតគាមអនាម័យ អាចចូលចតនៅកំពង់ផែបានលុះត្រាតែមានការអនុញ្ញាតពីសមត្ថកិច្ចភូតគាមអនាម័យ បន្ទាប់ពីមានការត្រួតពិនិត្យរួច ។

មាត្រា ២៣.-

សមត្ថកិច្ចភូតគាមអនាម័យ ត្រូវបន្តការត្រួតពិនិត្យ ណែនាំ និងតាមដានការដឹកជញ្ជូន ស្តុកទុក ការលក់ទំនិញ ជាកម្មវត្ថុនៃការត្រួតពិនិត្យភូតគាមអនាម័យ ចាប់ពីពេលចូលមកដល់ទឹកដី នៃព្រះរាជាណាចក្រកម្ពុជា ។ក្នុងករណីមានការលេចចេញ នូវសមាសភាពចង្រៃភូតគាមអនាម័យ ឬសមាសភាពចង្រៃបង្កគ្រោះថ្នាក់នៅទីកន្លែងណាមួយ សមត្ថកិច្ចភូតគាមអនាម័យ ត្រូវអនុវត្តវិធានភូតគាមអនាម័យជាបន្ទាន់ ។

## ជំពូកទី ៥

## ការត្រួតពិនិត្យភូតគាមអនាម័យ លើទំនិញនាំចេញ

មាត្រា ២៤._

ការត្រួតពិនិត្យការនាំចេញទំនិញ ជាកម្មវត្ថុនៃការត្រួតពិនិត្យភូតគាមអនាម័យ ត្រូវអនុវត្តតាមលក្ខខណ្ឌ ដែលមានចែងក្នុងបទប្បញ្ញត្តិ កិច្ចសន្យាពាណិជ្ជកម្ម កិច្ចព្រមព្រៀង អនុសញ្ញា និងបណ្តាឯកសារដទៃទៀត ស្តីពីលក្ខខណ្ឌ ភូតគាមអនាម័យនៃប្រទេសនាំចូល ។

មាត្រា ២៥._

លក្ខខណ្ឌនៃការនាំចេញទំនិញ ជាកម្មវត្ថុនៃការត្រួតពិនិត្យភូតគាមអនាម័យ មានដូចតទៅ :

១.ម្ចាស់ទំនិញត្រូវបំពេញសំណុំលិខិត សុំការត្រួតពិនិត្យភូតគាមអនាម័យ លើទំនិញរបស់ខ្លួនទៅសមត្ថកិច្ចភូតគាមអនាម័យ ដើម្បីទទួលបានវិញ្ញាបនបត្រភូតគាមអនាម័យ ។

២.ទំនិញត្រូវមានលក្ខណៈសមស្រប ទៅនឹងលក្ខខណ្ឌភូតគាមអនាម័យ នៃប្រទេសនាំចូល ដែលមានចែងក្នុងបទប្បញ្ញត្តិ កិច្ចសន្យាពាណិជ្ជកម្ម កិច្ចព្រមព្រៀង អនុសញ្ញា និងបណ្តាឯកសារដទៃទៀត ។

មាត្រា ២៦._

បែបបទនៃការត្រួតពិនិត្យភូតគាមអនាម័យលើ ទំនិញជាកម្មវត្ថុ នៃការត្រួតពិនិត្យភូតគាមអនាម័យនាំចេញ ត្រូវអនុវត្តតាមលក្ខខណ្ឌដែលមានចែងក្នុង មាត្រា៩ កឋាខណ្ឌទី១ មាត្រា១០ និងមាត្រា១៤ នៃអនុក្រឹត្យនេះ ។

## ជំពូកទី ៦

## ការត្រួតពិនិត្យភូតគាមអនាម័យ លើទំនិញដឹកជញ្ជូនឆ្លងកាត់

មាត្រា ២៧._

ការដឹកជញ្ជូនទំនិញ ជាកម្មវត្ថុនៃការត្រួតពិនិត្យភូតគាមអនាម័យ ឆ្លងកាត់លើទឹកដីនៃព្រះរាជាណាចក្រកម្ពុជាត្រូវគោរពតាមលក្ខខណ្ឌ ដូចតទៅ :

-ត្រូវមានវិញ្ញាបនបត្រភូតគាមអនាម័យ ដែលចេញដោយប្រទេសនាំចេញ

ត្រូវវេចខ្ចប់ទំនិញឱ្យបានគត់មត់ល្អ ធានាមិនរបើក ហើយផ្ទុកក្នុងកុងតេន័រ ដែលធានាមិនធ្លុះធ្លាយក្នុងពេលដឹកជញ្ជូន

-រាល់មធ្យោបាយដឹកជញ្ជូនទាំងអស់ ពុំត្រូវមានការចម្លង នូវសមាសភាពចង្រៃភូតគាមអនាម័យ ឬសមាសភាពចង្រៃបង្កគ្រោះថ្នាក់ ដែលអាចឆ្លងរាលដាលនៅតាមផ្លូវដឹកជញ្ជូនឆ្លងកាត់នេះ ។

មាត្រា ២៨._

បែបបទនៃការត្រួតពិនិត្យភូតគាមអនាម័យ លើទំនិញជាកម្មវត្ថុនៃការត្រួតពិនិត្យភូតគាមអនាម័យ ដឹកជញ្ជូនឆ្លងកាត់ត្រូវកំណត់ ដូចខាងក្រោម :

-ម្ចាស់ទំនិញត្រូវ ជូនដំណឹងដល់ទីស្នាក់ការត្រួតពិនិត្យភូតគាមអនាម័យ ដែលនៅជិតបំផុតនៅមុនពេលទំនិញទាំងនោះមកដល់ច្រកទ្វារព្រំដែនចូល និងច្រកទ្វារព្រំដែនចេញ

-សមត្ថកិច្ចភូតគាមអនាម័យ ត្រូវធ្វើការត្រួតពិនិត្យមធ្យោបាយដឹកជញ្ជូនផ្ទៃខាងក្រៅនៃបន្ទុកទំនិញ និងវិញ្ញាបនបត្រភូតគាមអនាម័យ របស់ប្រទេសនាំចេញ ហើយត្រូវសម្រួលឱ្យការដឹកជញ្ជូនបន្តបានឆាប់រហ័ស ។

មាត្រា ២៩._

នៅច្រកទ្វារព្រំដែនចូល នៃព្រះរាជាណាចក្រកម្ពុជា សមត្ថកិច្ចភូតគាមអនាម័យ ត្រូវអនុវត្តវិធានភូតគាមអនាម័យ មុននឹងអនុញ្ញាតឱ្យបន្តការដឹកជញ្ជូនក្នុងករណីពិនិត្យឃើញថា ទំនិញប្រាសចាកលក្ខខណ្ឌ ដូចមានចែងក្នុងមាត្រា ២៧ នៃអនុក្រឹត្យនេះ ។

ក្នុងករណីគ្រោះថ្នាក់ដោយចៃដន្យ ក្នុងពេលដឹកជញ្ជូន បណ្តាលឱ្យមានការបាក់បែក ឬ របើកសម្ភារៈវេចខ្ចប់ទំនិញ ម្ចាស់ទំនិញត្រូវរាយការណ៍ជាបន្ទាន់ ដល់សមត្ថកិច្ចភូតគាមអនាម័យ ឬ អាជ្ញាធរដែនដីដែលនៅជិតបំផុត ។ សមត្ថកិច្ចភូតគាមអនាម័យ ត្រូវពិនិត្យ និងអនុវត្តវិធានភូតគាមអនាម័យជាបន្ទាន់ រួចផ្តល់នូវវិញ្ញាបនបត្រភូតគាមអនាម័យ សម្រាប់បន្តការនាំចេញ ។

## ជំពូកទី ៧

## សមត្ថកិច្ច របស់មន្ត្រីភូតគាមអនាម័យ

មាត្រា ៣០._

មន្ត្រីភូតគាមអនាម័យមានសមត្ថកិច្ច :

-ត្រួតពិនិត្យភូតគាមអនាម័យ និងអនុវត្តវិធានភូតគាមអនាម័យ លើមធ្យោបាយដឹកជញ្ជូន និងទំនិញ

ដែលជាកម្មវត្ថុនៃការត្រួតពិនិត្យភូតគាមអនាម័យ នៅតាមឃ្លាំងស្តុក រោងចក្រឈាហ្រាស ផ្ទៃដីផលិតកម្ម ឬ កសិដ្ឋាន

-ចងក្រងសំណុំរឿងកំណត់ហេតុនៃបទល្មើស និងបញ្ជូនសំណុំរឿងកំណត់ហេតុ នៃបទល្មើសទៅតុលាការ

ម្ចាស់កម្មសិទ្ធិ ឬ អ្នកកាន់កាប់អចលនទ្រព្យខាងលើ ត្រូវអនុញ្ញាតឱ្យមន្ត្រីភូតគាមអនាម័យ ចូលពិនិត្យ និងត្រូវជួយសហការផ្តល់ព័ត៌មាន ដល់មន្ត្រីភូតគាមអនាម័យ ។

មាត្រា ៣១.-

អាជ្ញាធរដែនដី ឬ អាជ្ញាធរមានសមត្ថកិច្ច ត្រូវជួយផ្តល់អន្តរាគមន៍ ក្នុងកិច្ចប្រតិបត្តិការភូតគាមអនាម័យ ក្នុងករណីមានការស្នើសុំ ពីមន្ត្រីភូតគាមអនាម័យ ។

## ជំពូកទី ៨
## ទោសប្បញ្ញត្តិ

មាត្រា ៣២.-

មិនអនុញ្ញាតឱ្យធ្វើការនាំចូល នាំចេញ ឬ ដឹកជញ្ជូនឆ្លងកាត់ចំពោះរាល់ការដឹកនាំទំនិញ ជាកម្មវត្ថុនៃការត្រួតពិនិត្យភូតគាមអនាម័យ ណាដែល :

-មិនអនុវត្តតាមនីតិវិធីដូចចែងក្នុងមាត្រា ៨ លើកលែងចំណុច ៤ ឬមាត្រា៣០ កថាខណ្ឌ១ នៃអនុក្រឹត្យនេះ

-ប្រាសចាកលក្ខខណ្ឌភូតគាមអនាម័យ នៃប្រទេសនាំចូល ឬមិនគោរពតាមវិធានភូតគាមអនាម័យ ដូចមានចែងក្នុងមាត្រា ១០ នៃអនុក្រឹត្យនេះ

-មិនគោរពតាមលក្ខខណ្ឌ ដូចមានចែងក្នុងមាត្រា២១ ២៦ ឬ២៨ នៃអនុក្រឹត្យនេះ ។

មាត្រា ៣៣.-

ត្រូវពិន័យដោយយោងតាមមាត្រា ៦២ ជំពូកទី៧ នៃច្បាប់ស្តីពីការគ្រប់គ្រងគុណភាពសុវត្ថិភាព លើផលិតផលទំនិញ និងសេវា ចំពោះជនណាដែល :

- មិនគោរពតាមនីតិវិធី ដូចមានចែងក្នុងមាត្រា៨ ចំណុច៤ នៃអនុក្រឹត្យនេះ

-ប្រព្រឹត្តល្មើសនឹងមាត្រា១៣ កថាខណ្ឌ២ ឬ មាត្រា១៨ កថាខណ្ឌ២ ឬ មាត្រា១៩ ឬ មាត្រា២២ កថាខណ្ឌ២ ឬ៣ នៃអនុក្រឹត្យនេះ ។



ル

### មាត្រា ៣៤.-

ក្នុងករណីមិនរាងចាល ចំពោះបទល្មើសនឹងមាត្រា ១៨ កថាខណ្ឌ ២ ឬ មាត្រា ១៩ ឬ មាត្រា ២២ កថាខណ្ឌ ៣ នៃអនុក្រឹត្យនេះ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ទ្វេដង ដោយពុំទាន់គិតបញ្ចូលនូវទោសព្រហ្មទណ្ឌ ។

ក្នុងករណីបច្ច័យនៃបទល្មើស ដែលបង្កឱ្យមានការរាលដាលឆ្លង សមាសភាពចង្រៃភូតគាមអនាម័យ ឬ សមាសភាពចង្រៃបង្កគ្រោះថ្នាក់នោះ ជនល្មើសត្រូវពិន័យបន្ថែម នូវការចំណាយក្នុងការលុបបំបាត់បញ្ហាខាងលើ ដោយយោងតាមការកំណត់ ដោយប្រកាស របស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

### មាត្រា ៣៥.-

ត្រូវពិន័យដោយយោងតាមមាត្រា ៦៣ ជំពូកទី ៧ នៃច្បាប់ស្តីពីការគ្រប់គ្រងគុណភាព សុវត្ថិភាពលើផលិតផលទំនិញ និងសេវា ចំពោះជនណាដែលបាន :

ក.ធ្វើឱ្យសមត្ថកិច្ចត្រួតពិនិត្យភូតគាមអនាម័យ ដូចមានចែងក្នុងមាត្រា ៣ នៃអនុក្រឹត្យនេះ ពុំអាចបំពេញភារកិច្ចបាន ទោះបីក្នុងរូបភាពណាក៏ដោយ

ខ.ប្រកែកពុំព្រមបង្ហាញសំណុំឯកសារដែលពាក់ព័ន្ធ ឬមានចេតនាផ្តល់ព័ត៌មានមិនពិត ឬធ្វើឱ្យមានការភ័ន្តច្រឡំ ដល់ការដឹកជញ្ជូនទំនិញជាកម្មវត្ថុ នៃការត្រួតពិនិត្យភូតគាមអនាម័យ ។

គ.ចាត់ចែងដោយគ្មានការអនុញ្ញាត នូវទំនិញជាកម្មវត្ថុនៃការត្រួតពិនិត្យភូតគាមអនាម័យ ដែលត្រូវសមត្ថកិច្ចភូតគាមអនាម័យ ឃាត់ទុកជាបណ្តោះអាសន្ន ។

ឃ.ដឹកនាំទំនិញ ជាកម្មវត្ថុនៃការត្រួតពិនិត្យភូតគាមអនាម័យ គេចចេញពីទីស្នាក់ការត្រួតពិនិត្យភូតគាមអនាម័យ ក្នុងគោលបំណងគេចពីការត្រួតពិនិត្យ របស់សមត្ថកិច្ចត្រួតពិនិត្យភូតគាមអនាម័យ ។

### មាត្រា ៣៦.-

ជនប្រព្រឹត្តល្មើសមិនព្រមបង់ប្រាក់ពិន័យ ត្រូវរៀបចំសំណុំរឿងបញ្ជូនទៅតុលាការ ។

រង្វាន់លើកទឹកចិត្តដល់អ្នកមានស្នាដៃ និងចំណាយផ្សេងៗក្នុងការបំពេញបេសកកម្មនេះ ត្រូវកំណត់ដោយប្រកាសរួម របស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។



ũ

# ជំពូកទី ៩

# អវសានប្បញ្ញត្តិ

**មាត្រា ៣៧.-**

អនុក្រឹត្យលេខ ៩៨ អនក្រ. ចុះថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ១៩៨៣ ស្ដីពីការត្រួតពិនិត្យភូតគាមអនាម័យលើផលិតផលរុក្ខជាតិ នាំចេញ និងនាំចូល និងបទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍។

**មាត្រា ៣៨.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ២០០៣

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួងស្ថាប័ន
- គ្រប់សាលាខេត្ត -ក្រុង
- ដូចមាត្រា ៣៨
- ឯកសារ-កាលប្បវត្តិ

លេខ : ០៦៨ ចល.កសក

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម និងបញ្ជូនមក :

-ឯកឧត្តម លោកប្រធានគ្រប់អង្គភាពក្រោមឱវាទ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

- លោកប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និង នេសាទគ្រប់ខេត្ត-ក្រុង

ដើម្បីអនុវត្ត

ភ្នំពេញ . ថ្ងៃទី ០៣ ខែ ០៥ ឆ្នាំ ២០០៣

ត.ប : រដ្ឋ ម ន្ត្រី

អគ្គនាយក

គុំ-សារ៉ុន

លេខ:..143.....ចលនក្សកដក.រប

បានថតចំលងត្រឹមត្រូវតាមច្បាប់ដើមនិងបញ្ជូនមក :

- គ្រប់ថ្នាក់ដឹកនាំនាយកដ្ឋាន
- លោកប្រធានគ្រប់ការិយាល័យ

" ដើម្បីជ្រាប "

- ការិយាល័យការពារដំណាំ

" ដើម្បីអនុវត្ត "

រាជធានីភ្នំពេញ.ថ្ងៃទី ២១ ខែ ៤ ឆ្នាំ ២០០៣

ប្រធាននាយកដ្ឋានក្សេត្រសាស្ត្រនិងកែលំអដីកសិកម្ម

(ហត្ថលេខា)

ងាស់ . សុខ